សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

Free

KhmerPost USA

www.khmerpostusa.com

FREE COPIES
Vol. 13. Issue #275
June 30, 2019
www.khmerpostusa.com
Office: 978-677-7163
Direct: 978-656-8141
Email: Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

### ឥទ្ធិពលចិនបច្ចុប្បន្នមកលើកម្ពុជា

*សូមអានទៅទំព័រទី ០២*



ចិន និងវៀតណាមមានឥទ្ធិពល ខុសគ្នាលើកម្ពុជា

### វិស្សមកាលដំបូងនៅឆ្នេរសមុទ្រ "ខេបខត Cape Cod" ចុងប៉ូចនៃអាមេរិកា

*សូមអានទៅទំព័រទី ០៦*



# LITTLE ROADY SHUTTLE TO AID RESEARCH ON ON AUTONOMOUS VEHICLE TECHNOLOGY IN RHODE ISLAND

By KhmerPost USA




Providence, RI —Governor Gina Raimondo, Rhode Island Department of Transportation (RIDOT) Director Peter Alviti, Jr., along with state and local officials launched the Little Roady autonomous vehicle pilot project last month.

*Please see Litter Roady/14*

### *អង្គការម៉ារីម៉ាក វ៉ាលី ហ្វូតប៊ែង ជួយឧបត្ថម្ភដល់កម្មវិធីការហូបអាហាររដូវក្តៅរបស់ក្រសួងកសិកម្មសម្រាប់យុវជនអាយុ១៨ រឺដែលមានអាយុក្រោមនេះ*

តទៅទំព័រទី ១២

### *Merrimack Valley Food Bank Sponsors USDA Summer Eats Program: Kids 18 And Under Enjoy Free Food And Fun!*

*Please see USDA Summer Eats / 03*





មេធាវី លុយ ហាស្កែល

LAW OFFICE OF LOUIS S. HASKELL

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបំរើលោកអ្នកយ៉ាងល្អនាពេលអនាគត។

បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

*Excellent Service Since 1987*

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

LAW OFFICE OF LOUIS S. HASKELL • 16 PINE STREET • LOWELL, MA • (978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

"វិភាគនយោបាយពិភពលោក"

# ឥទ្ធិពលចិនបច្ចុប្បន្នមកលើកម្ពុជា

ដោយ ពិន សំខុន

ពលរដ្ឋខ្មែរកំពុងខ្វល់ខ្វាយពីប្រទេសចិនកំពុងពង្រីកឥទ្ធិពលប្រទេសខ្លួន មកលើកម្ពុជា ហើយធ្វើឱ្យប្រទេសកម្ពុជាបាត់បង់អធិបតេយ្យភាព ហើយក៏នឹងអាចបាត់បង់ទឹកដីបុព្វបុរសថែមទៀតផង។ គេនៅចាំថា កាលពីឆ្នាំ១៩៧៩ ចិនធ្លាប់មកវាយយួនបណ្តេញចេញពីការលុកលុយកម្ពុជា ហេតុអ្វីក៏ពេលនេះចិនមករំលោភកម្ពុជាដោយខ្លួនឯងទៅកើត?

•**<u>ចិននៅកម្ពុជា:</u>** ពលរដ្ឋខ្មែរបានស្គាល់ជនជាតិចិនច្បាស់ណាស់ ធ្លាប់មានព្រំប្រទល់ជាប់គ្នាពិអតីតកាល ហើយក៏មានប្រវត្តិសាស្ត្រជិតស្និតនឹងគ្នាថែមទៀតផង ក៏មិនដែលបៀតបៀនគ្នាដែរ។ បើតាមយើងស្គាល់ចិន គឺជាពលរដ្ឋដែលឧស្សាហ៍ ព្យាយាមច្រើនស្មោះត្រង់ គ្រួសារនិយម ពូកែររកស៊ី ចូលចិត្តទៅកាន់ដីថ្មីសម្រាប់ពង្រីកការរកស៊ី ដោយឃើញខ្លួនឯងចង្អៀត ដូច្នេះតើចិនដែលមកស្រុកខ្មែរនោះវាខុសពីចិនដែលយើងធ្លាប់ស្គាល់នោះដែរឬទេ?

ពួកជនជាតិចិនបានមកបំពុលខ្មែរយើង ដោយធន់ធានដោយទិញដីធ្លី ដោយសានសង់សំណង់ស្ទឹមស្ទែ ដោយការមករកស៊ីលុយបានហូរចូលគគ្រឹកគ្រេង, ចំណោកឯខ្មែរក៏បានទទួលផលចំណេញជាសម្បត្តិមហាសាលរៀងៗខ្លួនដែរ អ្នកដែលមិនធ្លាប់មានលុយវាល់លាន ក៏ក្លាយជាសម្បូរសប្បាយអស់ទៅហើយ... ទាំងនេះដោយប្រើច្បាប់ខ្មែរ ដោយប្រើថ្នាក់ដឹកនាំខ្មែរ ដោយប្រើភាពទន់ខ្សោយនៃរចនាសម្ព័ន្ធរដ្ឋបាលខ្មែរ នឹងភាពទន់ខ្សោយនៃវប្បធម៌ខ្មែរស្របគ្នា ។ ដោយសារវត្តមានចិនបច្ចុប្បន្ន ពលរដ្ឋ


ប្រធានាធិបតី ស៊ី ប្រទេសចិន


សម្តេចសីហនុ
ទទួលឥទ្ធិពលប្រទេសចិន


លោក ហ៊ុន សែន
ទទួលឥទ្ធិពលវៀតណាម និងមកចិន

ខ្មែរជាច្រើនក៏បានក្លាយជា"មីលីយូនែ"ឬក៏ពាក់កណ្តាលសម្បត្តិស្តុកស្តម ដ៏ចំនួនច្រើនណាស់ទៅហើយ ដែរខ្លះក៏មិនដឹងជាយកលុយទៅធ្វើអ្វីនៅឡើយទេផង ។ តើយើងត្រូវបន្ទោសចិន ឬក៏បន្ទោសខ្មែរគ្នាឯងជាម្ចាស់ស្រុកទៅវិញ? ប្រទេសថៃ ប្រទេសម៉ាឡេស៊ី គេការពារប្រទេសគេបានល្អណាស់ នេះក៏ព្រោះតែចិន ក៏គេគោរពច្បាប់របស់ប្រទេសដែលខ្លួនទៅរកស៊ីដែរ។

•**<u>វៀតណាមនៅកម្ពុជា:</u>** ខុសពីប្រទេសវៀតណាម ដែលបានមកជួយកម្ពុជា ពីឆ្នាំ១៩៧៩-៩០ មិនបានធ្វើឱ្យប្រទេសកម្ពុជាជឿនលឿនសម្បូរសប្បាយសូម្បីតែមួយចំណិតក៏គ្មាន ខ្មែររឹតតែក្រទៅរឹតតែខ្សោយទៅសំណាងល្អបានព្រឹត្តិការឆ្នាំ១៩៩៣ក៏មកដល់អង្គការសហប្រជាជាតិបាននាំយកលទ្ធិប្រជាធិបតេយ្យនឹងការគ្រប់គ្រងប្រទេសឱ្យទៅជាម្ចាស់ការខ្លួនឯងបាន ហើយបានបណ្តេញយួនចេញពីកម្ពុជា... ក៏ប៉ុន្តែភាគីខ្មែរនៅតែចង់ក្រាញរក្សារបបកុម្មុយនិស្ត (ហ៊ុន សែន) នឹងរបបក្រាបលូនរណោបរណើប (សម្តេចស៊ីហនុ) មកគ្រប់គ្រងប្រទេសដដែល ។ គេនាំគ្នាចាញ់ប្រាជ្ញ ហ៊ុន សែន ហើយធ្វើឱ្យបុរសខ្លាំងនោះ គ្រប់គ្រងកម្ពុជាតាមរបៀបផ្តាច់ការ -គ្រួសារនិយមដោយប្រើកម្លាំងវៀតណាម អស់រយៈជាង២០ឆ្នាំបន្តបន្ទាប់យ៉ាងគួរឱ្យស្តាយ។ តែក្រោយមក ហ៊ុន សែន អាចធ្វើនាយករដ្ឋមន្ត្រីដ៏យូរនេះបាន ក៏ព្រោះតែគណបក្សប្រឆាំងខ្មែរខ្សោយពេក។

•**<u>ប្រទេសខ្មែរត្រូវការគណបក្សប្រឆាំង:</u>** ប្រទេសខ្មែរត្រូវការណាស់នូវគណបក្សប្រឆាំងដ៏មាំទាំមួយក្នុងរចនាសម្ព័ន្ធរដ្ឋបាលសព្វថ្ងៃ សម្រាប់ទប់ទល់នឹងការរំលោភអំណាចនានា ឬក៏ការ មើលស្រាលរបស់រដ្ឋាភិបាល នឹង ដើម្បីជាទីទុកចិត្តរបស់រាស្ត្រម្ចាស់ឆ្នោត ដែលគេក៏អាចនឹងប្តូរដៃអ្នកកាន់អំណាចក្នុងប្រទេសក៏បានដែរ ។ កម្ពុជាសព្វថ្ងៃ កំពុងតែរងគ្រោះ

តទៅទំព័រទី ០៩




មណ្ឌលពិនិត្យសុខភាពឡូវែល

**Lowell Primary Care Center**

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

Sokharith Mey, M.D. Chhan Touch, C.N.P.

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients



ជំងឺទូទៅ សុខភាពផ្លូវចិត្ត

*Family Medicine & Behavioral Health*

អាស័យដ្ឋាន

1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992

ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking

# USDA Summer Eats /From Front Page




By KhmerPost USA

Lowell, MA – The Merrimack Valley Food Bank announces today that the organization is once again sponsoring the USDA Summer Eats Program 2019. Kids 18 and under can enjoy free food and fun activities at multiple locations throughout Lowell on weekdays from July 8, 2019 to August 23, 2019. The summer lunch program provided over 10,543 *Please see* es and snacks to children involved in activities at city parks, recreational centers, summer school programs and summer youth programs during summer 2018. "We coordinate with local partners to ensure that children participating in the Summer Food Service Program learn about healthy eating and staying physically active. The Merrimack Valley Food Bank's priority and mission is to serve nutritious food to Lowell children and help them enjoy a healthy, safe and active summer" said Tammie Dubois, Director of Programs.

Meals will be provided at a first come, first serve basis to all children without charge at the following locations

listed on the flyer.

No registration or I.D. is necessary. In accordance with Federal civil rights law and U.S. Department of Agriculture (USDA) civil rights regulations and policies, the USDA, its Agencies, offices, and employees, and institutions participating in or administering USDA programs are prohibited from discriminating based on race, color, national origin, sex, disability, age, or reprisal or retaliation for prior civil rights activity in any program or activity conducted or funded by USDA.

This institution is an equal opportunity provider.

For more information visit www.mvfb.org or contact Tammie Dubois at 978-454-7174 or email tdubois@mvfb.org.



# ជម្រើសសម្រាប់ប្រព័ន្ធបោះឆ្នោតថ្មី

ដោយ ពិន សំខុន

កាលពីលេខមុនយើងបាននិយាយថា "មានបណ្ដឹងបណ្ដាលឱ្យកិច្ចព្រមព្រៀងរវាងសាលាក្រុងឡូវែលនឹងមេធាវីក្រុមប្រជាជនភាគតិច"ដូច្នេះនៅមុនថ្ងៃទី៤ខែធ្នូ ប្រជាពលរដ្ឋឡូវែលនឹងទទួលបាននូវប្រព័ន្ធបោះឆ្នោតថ្មីមួយ ដែលនឹងមានប្រជាជនភាគតិច អាចនឹងឡើងកាន់អំណាចជាដំណាងរាស្ត្រ ក្នុងមណ្ឌលរបស់ខ្លួនបានជាលើកដំបូង តែប្រជាពលរដ្ឋត្រូវតែជ្រើសយកជម្រើសណាមួយកុំឱ្យច្រឡំ:

**ជម្រើសទីមួយ:** ១-សម្រាប់ដំណែងសមាជិកក្រុមប្រឹក្សាក្រុង

ទីក្រុងនឹងត្រូវបែងចែកជា៩សង្កាត់ -ដែលសង្កាត់និមួយៗត្រូវមានតំណាងជាប់ឆ្នោតម្នាក់ -ក្នុងសង្កាត់ទាំង៩ត្រូវឱ្យមានតំណាង

ជាប់ឆ្នោតជាជនភាគតិច យ៉ាងហោចណាស់ក៏២រូបដែរ ។

២-សម្រាប់ដំណែងគណកម្មការសាលារៀន

សង្កាត់ទាំងអស់ត្រូវរួមបញ្ចូលគ្នា បង្កើតជាមណ្ឌលតែ៣ សម្រាប់គណកម្មការសាលារៀនមួយ -សមាជិកគណកម្មការ២រូប ត្រូវ

ជ្រើសចេញពីមណ្ឌលនិមួយៗ - យ៉ាងហោចណាស់ក៏ត្រូវមានជនភាគតិចម្នាក់ជាប់ឆ្នោតក្នុងចំណោម៣នាក់ដែរ

**ជម្រើសទីពីរ:** ១-សម្រាប់ដំណែងក្រុមប្រឹក្សាក្រុង

ជាជម្រើសកូនភ្លោះ គឺអ្នកត្រូវឱ្យកំណើតដល់ដំណាងសង្កាត់ខ្លួនឯងផងនឹងឱ្យកំណើតដល់សង្កាត់ធំមួយ-ពីរ-បីទៀតផង:

(8+1):ក្នុងចំណោម៩ សង្កាត់៨ត្រូវជ្រើសតំណាង១រៀង១ខ្លួន, លើកលែងតែសង្កាត់ធំ១ត្រូវជ្រើសយកដំណាង ដោយការបោះឆ្នោតទូទាំងឡូវែលនៅពេលជាមួយគ្នាផង

(7+2):ក្នុងចំណោម៩ សង្កាត់៧ត្រូវជ្រើសដំណាង១រៀង១ខ្លួន លើកលែងតែសង្កាត់២ត្រូវជ្រើសដំណាងដោយការបោះឆ្នោតទាំងឡូវែល នៅពេល



ជាមួយគ្នា

(8+3):បង្កើតសង្កាត់ចំនួន១១ឱ្យសង្កាត់៨ត្រូវជ្រើររកដំណាង១រៀង១ខ្លួន លើកលែងតែសង្កាត់៣ធំ ត្រូវជ្រើសយកតំណាងទូទាំងឡូវែល៣រូប នៅពេលជាមួយគ្នា ។

ជាថ្មីម្ដងទៀត នៅក្នុងជម្រើសនិមួយៗ ត្រូវមានយ៉ាងហោចណាស់ក៏ជនជាតិភាគតិច ២នាក់ជាដំណាងរបស់សង្កាត់ដែរ ។

២-សម្រាប់ដំណែងសមាជិកគណកម្មការសាលរៀន:

(4 + 2) សង្កាត់៤ នឹងបោះឆ្នោតរើសសមាជិក៤រូបក្នុងសង្កាត់រៀង១ខ្លួន នឹងមាន២រូប ចេញពីការបោះឆ្នោតទូទាំងឡូវែល តែជាថ្មីម្ដងទៀត ត្រូវមាន២រូប ជាដំណាងឱ្យជនភាគតិច ។

**ជម្រើសទី៣** - សម្រាប់ដំណែងសមាជិកក្រុមប្រឹក្សាក្រុង

ជាប្រព័ន្ធជ្រើសរើស"សមាមាត្រ"ដែលនឹងផ្ដល់សន្លឹកឆ្នោតដល់បេក្ខជនណាដែលមានប្រជាប្រិយមានទម្ងន់ជាងគេ ។ ចំនួនអ្នកជាប់ឆ្នោត ទោះជាសមាជិកក្រុមប្រឹក្សាក្រុង ឬ គណកម្មការសាលារៀននឹងមិនមានផ្លាស់ប្ដូរទេ។

**ជម្រើសទី៤-** គឺជាការបោះឆ្នោតតាមបែបប្រមូលផ្ដុំវិធីទាំង៣ខាងលើផ្គុំគ្នា

ទីក្រុងនឹងចែកសង្កាត់ជា៣ ដើម្បីឱ្យពលរដ្ឋជ្រើសរើសសមាជិកក្រុមប្រឹក្សាក្រុង៣រូប នឹងគណកម្មការសាលារៀន២រូប ក្នុងសង្កាត់និមួយៗរបស់ខ្លួន, ដូច្នេះក្រុងទាំងមូលនឹងទទួលបាននូវសមាជិកក្រុមប្រឹក្សាក្រុង ចំនួន៩រូប នឹងគណកម្មការសាលារៀន៦រូប។

យោងតាមសេចក្ដីប្រកាសព័តិមានពីសាលាក្រុងបានឱ្យដឹងថា"ទាំងអស់គ្នានឹងមានពេលគ្រប់គ្រាន់សម្រាប់ពិនិត្យឡើងវិញ នឹងស្ដាប់អ្នកជំនាញ មុនពេលដែលក្រុមប្រឹក្សាក្រុងជ្រើសយកជម្រើស២មកដាក់លើសន្លឹកឆ្នោតនៅខែវិច្ឆិកា នៅក្នុងសំនួរក្រៅពីបោះឆ្នោត"ដើម្បីឱ្យក្រុងឡូវែល អាចសម្រេចយកជម្រើសណា១បាន សម្រាប់ការបោះឆ្នោតប្រព័ន្ធថ្មី នៅឡូវែលឱ្យបានមុនថ្ងៃទី៤ធ្នូជាកំហិត។

## បណ្ដឹងស្ដីពីប្រព័ន្ធបោះឆ្នោតថ្មី

ដើម្បីឱ្យបានយល់ពីប្រព័ន្ធបោះឆ្នោតថ្មីនៅឡូវែល សម្រាប់ឆ្នាំ២០២១ ពីការដែលសាលាក្រុងឡូវែលបានចរចាជាមួយក្រុមដាក់ពាក្យបណ្ដឹង ដើម្បីកុំឱ្យបន្តការប្ដឹងផ្ដល់គ្នា, សហគមន៏ខ្មែរប្រមាណ១០នាក់ តាមការអញ្ជើញ"សមាគមអេសេឡិក"







បានជួបជាមួយលោក ដូមីណិក ឡាយ សមាជិកគណកម្មការសាលារៀន កាលពីថ្ងៃសុក្រទី២៨ កន្លងទៅ -លោកបាននិយាយប្រាប់អង្គប្រជុំស្ដីពីប្រព័ន្ធបោះឆ្នោតថ្មីថា"ពាក្យថាតំណាងរបស់សង្កាត់District Representation ពុំមែនបានន័យថាខ្មែរនឹងជាប់ឆ្នោតនៅតំបន់ដែលខ្មែររស់នៅច្រើននោះទេ...តែបើបានន័យយ៉ាងនោះមែន ខ្ញុំថាក្រុមខ្មែរទៅប្ដឹងផ្ដល់រកវិធីបង្កើតតំណាងនៅតំបន់គឺដើម្បីឱ្យគេចងដៃខ្លួនឯងទៅវិញទេ ដូច្នេះខ្ញុំមិនយល់ស្របឱ្យប្ដូរផ្លាស់អ្វីទេ!..."។

លោកអភិបាលក្រុងរង វាស្នា នួន ដែលបានចូលមករួមប្រជុំនៅពេលបន្តិចក្រោយមកបានបញ្ជាក់ថា"គោលការដែលថាមានជម្រើស៤យ៉ាងដើម្បីស្នើទៅពលរដ្ឋឡូវែលមែន តែឥឡូវនៅសល់តែ២ទេដែលត្រូវដាក់ឱ្យធ្វើប្រជាមតិគឺទី១-សម្រាប់ក្រុមប្រឹក្សាក្រុងការបោះឆ្នោតកូនកាត់ (8+3) ។ ទី២-ការបោះឆ្នោតតាមការឱ្យលំដាប់ថ្នាក់ដែលខ្លួនចូលចិត្ត... ។

យើងនឹងធ្វើអត្ថាធិប្បាយនៅពេលក្រោយទៀត។





មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

LYNN PRIMARY CARE CENTER
មណ្ឌលពិនិត្យសុខភាពលីន

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

# MCC's College for Kids Cultivates Artistic Expression

By KhmerPost USA

Keeping kids busy during summer can be tough. Middlesex Community College offers several courses this year and it's not too late to register yet.

The program runs from July 8 through Aug. 15. One- and three-week, full- and half-day summer programs for children and teens (ages 8 to 17) are offered in Bedford and Lowell. Here's a sampling of arts programs offered this summer:

Creative Sculpture – Combine engineering with art to create sculptures with recycled materials. (Ages 8-12; offered July 8-11

Creative Writing – Develop your skills as an up-and-coming writer. (Ages 10-15; offered July 8-11

Fashion Design – Explore fashion tools and techniques, and develop your own style. (Ages 12-16; offered July 8-11

Choreography – Dancers can explore a variety of styles of dance while learning how to use their own creative voice. (Ages 8-16; offered July 15-18

Exploration Art Studio – A variety of art materials will be at your disposal to create what interests you! (Ages 8-12; offered July 15-18

Advanced Digital Photography – Learn about new photographers, digital artists and more sophisticated techniques. (Ages 12-17; offered July 29-Aug. 1

For the complete MCC College for Kids 2019 schedule and registration information, visit https://www.middlesex.mass.edu/collegeforkids or call 781-280-3663.








# វិស្សមកាលដំបូងនៅឆ្នេរសមុទ្រ "ខេបខត Cape Cod" ចុងប៉ូចនៃអាមេរិកា

ដោយ ពិន សំខុន

ឡូវែល: សិស្សឈប់រៀនវិស្សមកាលធំ ១សប្តាហ៍ទៅហើយ យើងនៅមិនទាន់ចេញទៅកំសាន្តឯណានៅឡើយ រីឯនៅរដ្ឋម៉ាសាឈូសិត នឹងតំបន់ជុំវិញ ក៏មិនខ្វះរមនីយដ្ឋានសម្រាប់កំសាន្តដែរ ។ នៅទីបញ្ចប់នៃរដូវត្រជាក់ ដែលយើងធ្លាប់រស់នៅដូចសត្វកណ្តុរក្នុងរូង យើងក៏ណាត់គ្នាជាមួយគ្រួសារ សារិទ្ធ ទៅលេងមាត់សមុទ្រ "ខេបខត" ដ៏ល្បីល្បាញ នៃសហរដ្ឋអាមេរិកឱ្យបានម្តង ។

ព្រឹកថ្ងៃសៅរ៍ទី២២មិថុនានេះ វេលាម៉ោង១០ព្រឹក ថ្ងៃត្បិតតែជាថ្ងៃឈប់សម្រាកមនុស្សម្នាចេញឡានថ្មីៗរបស់ខ្លួនពេញផ្លូវយ៉ាងចង្អៀត រួចទៅហើយ យើងក៏បើកឡានតាមគេឯងយ៉ាងយឺតៗទៅកាន់គោលដៅរបស់យើង ។ ទេសភាពត្រកាលនៅតាមផ្លូវ ដែលយើងធ្លាប់ជិះឡានកាត់ ក៏បានផ្លូវពណ៌ខុសគ្នាជារៀងរាល់ថ្ងៃ ទៅតាមរដូវរបស់គេដែរ មិនបានធ្វើឱ្យយើងធុញទ្រាន់ទេ ។ យើងសំដៅទៅចុងច្រមុះ នៃសហរដ្ឋទីដែលកាលពីអតីតកាល មាននាវាសំពៅសមុទ្រដំបូងមកពី "អឺរ៉ុប" ធ្លាប់ចូលសំចត គេច្រឡំថាជាប្រទេសឥណ្ឌា ទើបគេសរសេរសៀវភៅប្រាប់គ្នាគេថា ម្ចាស់ស្រុកខ្មៅៗនោះ ជាជនជាតិ "ឥណ្ឌាន" តែតាមពិតជា "អាមេរិកាំងស្បែកក្រហមម្ចាស់ស្រុក" សោះ ។ មកទល់សព្វថ្ងៃនេះ សហព័ន្ធរដ្ឋម៉ាសាឈូសិត នៅកាន់កាប់ដោយទទួលស្គាល់តំបន់ជាច្រើន ថាជាទឹកដី




គ្រួសារខ្មែរនៅឡូវែលគួរតែឧស្សាហ៍ទៅលេខមាត់សមុទ្រក្បែរៗនេះនារដូវក្តៅ

"ការពាររបស់អាមេរិកាំងស្បែកក្រហមម្ចាស់ស្រុក" នៅឡើយ ហើយអាមេរិកាំងស្បែកក្រហមទាំងនោះ ក៏ជាពលរដ្ឋអាមេរិកាំងពេញសិទ្ធិដូចគេឯងទាំងអស់គ្នា ។

យើងជិះរថយន្តតាមមហាវិថី កាត់តាមតំបន់ដែនដីកាពារទាំងនោះ ឆ្លងស្ពានអាយុរាប់រយឆ្នាំ ទៅកាន់ចុងច្រមុះនាឆ្នេរខាងកើតនៃសហរដ្ឋអាមេរិកនោះ ក្នុងដំណើរជាង៣ម៉ោងយ៉ាងខ្លីដោយ សារិទ្ធ និយាយលេងតាមផ្លូវមិនចេះចប់ ជជែកគ្នាជាមួយ "លុច" កូនប្រុសខ្ញុំជាអ្នកបើកឡាន ហើយទើបតែត្រឡប់មកពីកម្ពុជា មកលេងឡូវែលជាលើកដំបូង ចំណែកខ្ញុំជាអ្នកដេកស្តាប់ ញូខ្លះអត់ខ្លះ នឹងគេទៅ -ចំណែក ប៉ុណ្ណារ៉ូ នឹងកូនស្រី របស់ សារិទ្ធ អាយុប្រហែលគ្នានាំគ្នាលេងនៅបាំងខាងក្រោយយ៉ាងគ្មានរំខាន ។

ចតឡាននៅចំណតមាត់សមុទ្រ នៃតំបន់មាត់សមុទ្រ "ដានីស" មែនគេមិនសូវស្លៀកពាក់ធ្ងន់ ឬច្រើនទេទាំងស្រីទាំងប្រុស គេនិយមរីករាយនឹងបង្ហាញស្បែកទៅកាន់ពន្លឺថ្ងៃ ជាពិសេសស្រីៗ ដែលបុរស "ខ្មែរ" ហៅថា "អាសអាភាស" តែចូលចិត្តមើលណាស់ យើងក៏បានតាំងទីបោះបង្គោល អង្គុយសំដិល "អាំងង្សៀត" ដូចគេឯងទៅ នៅក្បែរនារីៗ ដែលមិនចូលចិត្តបិទបាំងដើមទ្រូង កំប៉េះគូថ នឹងគល់ភ្លៅនោះទៅ ។ សមុទ្រក្រៅ ដែលមានរលកតូចៗ ដោយសារមាន



ខ្យល់តិចៗ ផ្តើមមានមនុស្សមកកំសាន្តមានភោជនីយដ្ឋាន មានមនុស្សការពារសន្តិសុខ មានអ្នកសំអាតទីធ្លា ធ្វើឱ្យតំបន់ស្អាតដោយសោភណ្ឌភាពនឹងការថែរទាំប្រកបដោយស្រឡាញ់ក្លាយជាទីគួរឱ្យចូលចិត្តណាស់ ។


Bundle up for savings



When you choose Allstate to protect what matters most, you get an expert agent who will make it easy for you to save. Like with bundling your insurance. It's the simplest way for you to save time and money, while getting protection for the things that matter most. Stop by or call today and let's get you bundled up.



Chennara Kim
Associate Agent
The Wicks Insurance Group, Inc.
978-710-7040
83 Parkhurst Road
Chelmsford, MA 01824
chennarakim@allstate.com

Allstate.
You're in good hands.

យើងខ្ញុំអាចនិយាយភាសាខ្មែរ

Subject to terms, conditions & availability. Savings vary. Allstate Vehicle and Property Insurance Co., Allstate Insurance Co. © 2019 Allstate Insurance Co.

9966453





CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខ័ម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY

77 E. Merrimack Street, Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# ក្រុមតុកាហ្វេ“ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ” នៅឱកាសបុណ្យទិវាឪពុក

ឡូវែល: ក្រុមខ្មែរតែងជួបជុំគ្នានៅតុកាហ្វេ តែងមិនចូលចិត្តសែពគុបមនុស្សដែលធ្វើឱ្យមានការកត់សំគាល់ថា ជាមនុស្ស"ឆ្អិនក្បាលស៊ីក្បាលឆ្អិនកន្ទុយស៊ីកន្ទុយ" ពីព្រោះគេថា ជាមនុស្សមានចារិកមិនទៀងត្រង់ មិនអាចទប់ចិត្តមិនឱ្យចង់បាននោះទេ ដូចជាចង់ល្អ ចង់ហូប ឬ ដែលសំខាន់នោះ គឺចង់ស្រី។ ប៉ុន្តែ...ជាចៃដន្យ កាលពីថ្ងៃអាទិត្យបុណ្យ "ហ្វាឌ័រដេយ Father Day" ២០១៨នេះ ... មេក្លោងគេថ្ងៃនេះ មានឈ្មោះថា"ល្បួងសៀង"...។

តាំងតែពីថ្ងៃត្រង់ ហៅរកនរណាក៏មិនឆ្លើយ បានកូនចៅម្នាក់នៅក្បែរខ្លួនឈ្មោះ លីតុង ឈុង ក៏បញ្ជាដាច់ណាត់ឱ្យចាប់កន្ធែកជើងកូនជ្រូកមួយ ដើម្បីឱ្យគាត់បុកនឹងច្បូកដែកវែងដ៏ពិសេសមួយ ប្រើសម្រាប់ឆ្កាង ដោតជ្រូកក្មេងនោះ ពីខាងជើងសំដៅទៅក្បាល រហូតបានជោកជ័យទើបញញឹមបន្តិចតែនៅតែរអ៊ូថា "ហៅនរណាក៏មិនចូល! ហៅនរណាក៏មិនលើក!..." ម៉ោង១កន្លះរសៀល ជ្រូកឡើងបង្គងទៅហើយ នៅតែមិនទាន់មានគ្នាមកនៅឡើយ ភ្លៀងនៅតែធ្លាក់តែទេព្តានៅតែមិនអាចធ្វើឈ្នះ"ល្បួងសៀង"បានទេត្បិតតែគាត់អាំងកូនជ្រូកនៅក្នុងរោងជាងដ៏ធំទូលាយរបស់គាត់ បង្វិលឆ្វេងរួចបង្វិលទៅស្តាំលើរងើកភ្លើងក្រហមគ្មានផ្សែងជ្រូកគាត់ឡើងក្រហម តែមិនខ្លោចទេ រហូតដល់ហៀរខ្លាញ់ តក់ៗលើភ្លើងមិនឆេះជាអណ្តាតភ្លើងទៀត,។

គាត់ក៏ឱ្យគេមកបង្វិលជ្រូកខ្វៃជំនួសគាត់ អ្នកជំនួសនោះក៏ជាជើងខ្វៃជ្រូកជំនាញម្នាក់ដែរ បង្វិលបណ្តើរនិយាយបណ្តើរថា "អាជ្រូកកន្ទុយខ្លី ជាជ្រូកចិញ្ចឹមក្នុងទ្រុង ស្បែកវាមិនស្រួយទេ តែបើអាកន្ទុយវែងវិញ ជាជ្រូកក្រៅទ្រុង វាស៊ីចំណីគ្រប់មុខ





ស្បែកវាឆាប់ស្រួយឆ្ងាញ់ណាស់...!" ល្បួងសៀងបន្ទោសថា"អាកន្ទុយវែងកន្ទុយខ្លីអី...គេឱ្យបង្វិលហើយ ចេះតែបង្វិលទៅ!" ថាហើយក៏យកទឹកប្រេងមកលាបស្បែកដែលក្រហមស្រអាប់នោះ ឱ្យទៅជាក្រហមរលោងស្រិលទៅវិញ ប៉ុន្មានជា២០នាទីក្រោយមក គាត់ក៏យកសមដែក មកដាក់ជ្រុំលើស្បែកជ្រូកដែលឡើងក្រហម ស្ទើរគ្រប់កន្លែង ដូចជាធ្វើទារុណកម្មលើជ្រូកដែលខ្វៃទៅហើយនោះអីចឹង។។

នេះគឺនៅ១ម៉ោង២០នាទី ដែលជ្រូកនោះនៅលើភ្លើង... គឺ"ហ៊ាសៀង"គាត់ចាក់ស្បែកទម្លាយខ្លាញ់ដែលរលាយនៅក្រោមស្បែកឱ្យហៀរចេញមកក្រៅ...

អីយ៉ា ក្លិនឈ្ងុយទៅដល់ក្រៅផ្ទះហើយ... ថីក៏គេមិនដឹង? ឬទ្វីមកដល់មុនគេ ហើយបន្ទោសអ្នកមកដល់បន្ទាប់ គឺ"អ៊ុំស្រី"ដែលថា"ឱ្យតែឮថា មានជ្រូកខ្វៃត្រង់ណា គឺមកដល់តាមក្លិន មិនដែលខានទេ! "អ៊ុំស្រី"គឺត្រកូលហ៊ុម បានបង្ហាញភស្តុតាង ថា"មានអ្នករនុកក្នុងឱ្យការតាមហ្វេសប៊ុកមិនមែនមកដោយចិត្តឯងទេ!"។ ចាស់ៗស្រក់ទឹកមាត់ ជួបជុំគ្នា៥នាក់ រួច១០នាក់ "ល្បួងសៀន"ផ្តើមកាត់សាច់ចំហៀងពោះដែលឆ្អិនមុនគេមកភ្លក់ រួចកាត់សាច់ត្រចៀក មកហាន់ជាបន្ត, ខ្លាញ់រលាយចេញអស់ នៅសល់តែស្បែកនឹងសាច់តែម្តង ត្រូវមាត់អ្នកខ្លាចឡើង "កូឡេស្តេ

គឺខ្លាញ់នោះហើយដែលបំពងស្បែកជ្រូកឱ្យឡើងកន្ទួលៗ គឺជាទ្រង់ទ្រាយនៃស្បែកជ្រូកស្រួយ លេចរូបរាងមកហើយ... ភ្ញៀវក៏មកដល់ជាបន្តបន្ទាប់ដូចគេយកការបាន ថាម្ហូបជិតឆ្អិនហើយ!...តែតាមពិត លិតុង ឈុង

រូល"បាច់តែម្តង... ពេលនោះ ក៏បានត្រូវ"សារិទ្ធមាត់ដាច" បន្ទរថា "អាហ្នឹងបានគេហៅថា ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ" តែអាកន្ទុយខ្លីនោះ មិនត្រូវគេកាត់ស៊ីមុនគេទេ... រីឯកូនក្មេង ប៉ុណ្ណារ៉ូ នៅ

គោសង្កាក់មួយចានធំ ភរិយា"ល្បួងសៀង"ទម្លាក់បាញ់ហាយបន្ថែម... តែទោះជាភ្លៀងមិនព្រមឈប់"ហ៊ាសៀង"ក៏មិនព្រមចាញ់ នៅតែខ្វៃជ្រូកអស់២ ដោយមិនខ្វល់នឹងភ្លៀងផ្គរអ្វីទាំងអស់, ទិវា "ឪពុក"បានបន្ត





បានលួចបង្ហោះរូបជ្រូកខ្វៃច្រង៉ាងៗ ឱ្យក្រុមស៊ីផឹកដែលរង់ចាំម្ហូបឆ្អិនសិន សឹមមកដល់ល្ងាច មិនបាច់ចាំយូរ...!

ក្បែរនោះ សម្លក់មើលពិធីបូជាយញ្ញ"ជ្រូកកំសត់" ក៏ឧទ្ទានថា"ឃើញហើយលែងឃ្លានបាយ!" ឯចំណែកកុមារី ឡូរ៉ា វិញមិនខ្ចីហូបចំណីក្រៅផ្ទះសោះតែម្តង...។

"កុមារតារា"មកជាមួយគ្រួសារគាត់ នាំទាំងសាច់

ជាមួយភ្ញៀវមកតាំងពី"លីន-រីវែរ"ដល់ឡើង ណែនរោង រហូតដល់រាត្រីកាល។ ក្រុមឆ្អិនក្បាលមិនបានស៊ីកន្ទុយទេ គេនាំគ្នាប្រារព្ធទិវាឪពុក ប្រកបដោយមិត្តភាព តែបានទុកឱ្យលោកស្រីៗដែលជូនដំណើរប្តីដោយខ្លាចប្តីបើកឡានមិនបានស្រវឹងស្ទើរគ្រប់គ្នា។



# គុណប្រយោជន៍សម្រាប់សុខភាពក្រោយ ពីការទទួលទានពោតបារាំង



(អាមេរិក): ផ្លែ Okra ឬផ្លែពោតបារាំង ត្រូវបានក្រុមអ្នកស្រាវជ្រាវរកឃើញថាមានអត្ថប្រយោជន៍ជាច្រើនចំពោះសុខភាព ដោយយើងអាចទទួលទានទាំងស្រស់ ឬយកទៅចំអិន និងច្នៃជាមុខម្ហូបក៏បាន។

ជាក់ស្តែងខាងក្រោមនេះ គឺជាអត្ថប្រយោជន៍មួយចំនួននៃការទទួលតានផ្លែអូក្រា ឬផ្លែពោតបារាំង។

**១-មានអត្ថប្រយោជន៍សម្រាប់សុខភាពស្ត្រីមានផ្ទៃពោះ**

ផ្លែពោតបារាំង គឺសម្បូរទៅដោយសារជាតិហ្វូឡេត ដែលត្រូវបានក្រុមអ្នកស្រាវជ្រាវរកឃើញថា មានគ្រឿងផ្សំធម្មជាតិសំខាន់មួយសម្រាប់ស្ត្រីមានផ្ទៃពោះ ដើម្បីជួយបង្កើត និងការពារកោសិកាថ្មី។

ម្យ៉ាងវិញទៀត ពោតបារាំងសម្បូរទៅ ដោយវីតាមីន C ដែលអាចមានប្រយោជន៍ដល់ការលូតលាស់របស់ទារក។

**២-ជួយការពារជំងឺទឹកនោមផ្អែម**

សារជាតិសរសៃធម្មជាតិរបស់ពោតបារាំងជួយរក្សាលំនឹង និងបញ្ចុះជាតិស្ករនៅក្នុងឈាម។

**៣-មានប្រយោជន៍សម្រាប់អ្នកមានជំងឺក្រលៀន**

ការសិក្សាមួយបានរកឃើញថា ការទទួលផ្លែពោតបារាំងជាប្រចាំអាចជួយការពារជំងឺក្រលៀន មិនតែប៉ុណ្ណោះ វាថែមទាំងជួយប៉ូវក្រលៀន កុំឱ្យរងការខូចខាតផងដែរ។

**៤-ជួយការពារជំងឺហឺត**

ការសិក្សាមួយបានរកឃើញថា វីតាមីន C នៅក្នុងផ្លែពោតបារាំងអាចជួយសំរួលដល់ផ្លូវដង្ហើមរបស់អ្នកមានជំងឺហឺត។ មួយវិញទៀត ការសិក្សាក៏បានបង្ហាញថា ការទទួលទានផ្លែពោតបារាំងជាប្រចាំ អាចជួយកាត់បន្ថយអាការៈថប់ដង្ហើមផងដែរ។

**៥-ជួយធ្វើឱ្យស្បែកភ្លឺរលោង វីតាមីន C មានសារសំខាន់ខ្លាំងណាស់ សម្រាប់សុខភាពស្បែក។ វាអាចធ្វើឱ្យអ្នកមើលទៅក្មេងជាងវ័យ ព្រមទាំងជួយជួសជុលកោសិកាចាស់ៗចោល។**

នៅពេលដែលយើងស្ងោរផ្លែពោតបារាំងរហូតដល់ទន់ ហើយទុកវាឱ្យត្រជាក់ រួចក្រឡុកឱ្យម៉ដ្ឋ ហើយយកមកលាបលើមុខ។ បន្ទាប់មកទុកចោលរយៈពេល៥នាទី រួចលាងចេញដោយទឹកស្អាតនោះអ្នកមានផ្ទៃមុខទន់ និងភ្លឺរលោង។

**៦-ជួយដល់ការរំលាយអាហារ និងសម្រកទម្ងន់**

ផ្លែពោតបារាំងសំម្បូរទៅដោយសារជាតិសរសៃ ដែលអាចជួយដល់ការរំលាយអាហារ។ ម្យ៉ាងវិញទៀត វាអាចជួយដល់ការសម្រក់ទំងន់យ៉ាងមានប្រសិទ្ធភាព ដោយវាអាចជួយបំផ្លាយកាឡូរីនៅក្នុងរាងកាយ។

**៧-សម្បូរដោយសារធាតុរ៉ែ និង វីតាមីន**

ពោតបារាំងសម្បូរដោយសារជាតិរ៉ែ និងវីតាមីនសំខាន់ៗជាច្រើន ដែលនៅក្នុងនោះរួមមានសារជាតិសរសៃ ២,៥ ក្រាម, វិតាមីន C ១៦,៣ មីលីក្រាម, ហ្វូឡេត ២៦ មីក្រូក្រាម, វីតាមីន A និងវីតាមីន K ៤០មីលីក្រាម ព្រមទាំងវិតាមីនជាច្រើនផ្សេងទៀត ដែលមានអត្ថប្រយោជន៍ចំពោះសុខភាព។

**៨-ល្អចំពោះភ្នែក**

ពោតបារាំងសម្បូរដោយវីតាមីន A ,សារជាតិបេតាការ៉ូទីន, លូទីន និង សេនស៊ីន ដែលមានអត្ថប្រយោជន៍យ៉ាងប្រសើរសម្រាប់ភ្នែក ដែលអាចជួយកាត់បន្ថយអាការៈម្វូប និងឡើងបាយ។


ឥណទានផ្ទះ (ការខ្ចីសម្រាប់ទិញផ្ទះ)

✓ កម្មវិធីឥណទានទិញ និងការបង់ឡើងវិញ
✓ កម្មវិធីអ្នកទិញផ្ទះលើកដំបូង
✓ នឹងអាចមានទៅបាននូវកម្មវិធីអត្រាគង់ និងអត្រាផ្លាស់ប្តូរ
✓ ឥណទានអាស្រ័យតាមតម្លៃផ្ទះ
✓ ឥណទានសម្រាប់ការសាងសង់ទៅជាការខ្ចីរហូត

មជ្ឈមណ្ឌលនិក្ខេប
នៅធនាគារអេនធ័រប្រែស៍

978-656-5653 | 877-671-2265

ដាក់ពាក្យតាមអ៊ិនធឺណិតនៅ EnterpriseBanking.com/Mortgage



EnterpriseBanking.com/Mortgage

Enterprise Bank
CREATE SUCCESS

Member FDIC

តមកពីទំព័រទី ០២

# ឥទ្ធិពលចិនបច្ចុប្បន្នមកលើកម្ពុជា

ដោយរដ្ឋាភិបាលកំពុងជិះសេះលែងដៃគ្មាននរណាទប់ទល់ការ"រំលោភអំណាច"ក្នុងរចនាសម្ព័ន្ធរដ្ឋគ្មានការចែករំលែកធនធានដែលមានបានពីការរកស៊ីឱ្យបានជា"ប្រយោជន៍ដល់ដៃគ្រប់ៗគ្នា" ធ្វើឱ្យអ្នកក្រវ៉ាក្រហួសហេតុ រីឯអ្នកមានវិញ មានកប់ពពក។ ដូច្នេះអត់គណបក្សប្រឆាំងនៅកម្ពុជា គឺជាកង្វះដែលខានមិនបានទេ!

•**<u>គណបក្សប្រឆាំងនៅឯណា?</u> ឆ្នាំ១៩៩៣ទ្រង់នរោត្តម រណឫទ្ធ នៃគណបក្សហ្វុនស៊ិនប៉ិចៈ** កណបក្ស




ប្រធានស្តីទីកណបក្សសង្គ្រោះជាតិនៅបរទេស




ប្រធានកណបក្សសង្គ្រោះជាតិនៅក្នុងការឃុំឃាំង

លោកតា សឹង សាន ដែលឈ្នះឆ្នោត បានក្លាយជាគណបក្សកាន់អំណាចក្នុងលទ្ធិប្រជាធិបតេយ្យសេរីជាលើកដំបូង តាំងតែពីចំនួន៤០ឆ្នាំមកហើយ, ប៉ុន្តែមិនយូរប៉ុន្មាន ក៏ត្រូវសម្តេច ស៊ីហនុ នឹង ហ៊ុន សែន ដណ្តើមយកពីដៃដោយដាក់ឱ្យស្មើគ្នាជាមួយគណបក្សប្រជាជន រហូតដល់គេដណ្តើមយកអំណាចទៅវិញបាន យ៉ាងឆាប់រហ័សដោយការខ្វះសមត្ថភាព។ បន្ទាប់មកគណបក្សប្រឆាំងទី៣ មានគណបក្សជាតិខ្មែរដឹកនាំដោយ សម រង្ស៊ី ក៏បានកើតឡើងគួរឱ្យមានសង្ឃឹម ស្រាប់តែរវល់តែប្រទាញប្រទង់ជាមួយគណបក្សហ៊្វុនស៊ិនប៉ិច(ដែលជាគណបក្សភាគតិចដូចគ្នា)បន្ទាប់មក ប្រទាញប្រទង់ជាមួយគណបក្សសិទ្ធិមនុស្ស(ដែលកើតក្រោយគេ) ដោយមិនបានស្វែងរកឈាមថ្មី គំនិតថ្មីសម្រាប់ផ្លាស់ប្តូរ គណបក្សសម រង្ស៊ី ក៏ថមថយកម្លាំង រហូតដល់គណបក្សសិទ្ធិមនុស្សមានសន្ទុះលូតចេញមកយ៉ាងលឿន ធ្វើឱ្យលោក សម រង្ស៊ី សុខចិត្តយកគណបក្សសិទ្ធិមនុស្សធ្វើជាសម្ព័ន្ធមិត្រ។ ជំនួបគ្នានេះ បានផ្តល់ភាពរីកចំរើនដល់គណបក្សប្រឆាំង ដែលគេទស្សន៍ទាយថា"អាចមានលទ្ធភាពទប់ទល់គណបក្សប្រជាជនបាន" ប៉ុន្តែគណបក្សសម្ព័ន្ធភាពនោះមានឈ្មោះថា"គណបក្សសង្គ្រោះជាតិ"នៅមានបញ្ហាផ្ទៃក្នុងច្រើនពេកនៅឡើយ ធ្វើឱ្យគេជឿតែលើភាពអស់សង្ឃឹម ចូលចិត្តប្រថុយប្រថានមិនឈប់ឈរ និយាយចោលគ្មានគម្រោងមិនអាចងើបឈរជាបក្សប្រឆាំងដែលត្រូវការនោះបានទេ នៅពេលនេះ បើមិនមានមាយាតខ្លួនឯងជាមុន សឹមឱ្យបច្ចឹមប្រទេសជួយទេនោះ។

**កម្ពុជាឋិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បំផុតមួយៈ** ការគ្រប់គ្រងក្នុងប្រទេសខ្មែរសព្វថ្ងៃ គឺជាប្រព័ន្ធ"របបឃោធានិយមលាក់ខ្លួន ជាប្រទេសប្រជាធិបតេយ្យ" ការបោះឆ្នោត ឬប្រើច្បាប់ដោយសភាជាតិទាំងឡាយ សម្រាប់តែរស់ពី១ពេលទៅ១ពេលទៀត គ្មានស្ថេរភាពនយោបាយនឹងសេដ្ឋកិច្ចទេ ហេតុអ្វី? អាគារខ្ពស់ៗដុះដូចផ្សិតចំបើង ផ្លូវថ្នល់ខ្វាត់ខ្វែងរថយន្តថ្មីៗ ធំក៏មានតូចក៏មាន រត់ពេញផ្លូវ ផ្សារទំនើបនឹងបូរាណនៅពេញក្រុង...។ ប៉ុន្តែក្នុងចំណោមពលរដ្ឋ១៥លាននាក់ មានតែ១-២លានប៉ុណ្ណោះ ដែលទទួលផលច្រើន ឬតិចពីរូបភាពរីកចំរើននេះ។ ធនធានសម្បត្តិមហាសាលនោះ វាហូរមកពីណា? គឺពីបរទេសដែលមានបំណងយកអធិបតេយ្យភាពរបស់ខ្មែរ យកប្រទេសខ្មែរ គេដាក់លុយបំពុលជាតិឱ្យថ្នាក់ដឹកនាំខ្មែរធ្វើប្រយោជន៍ឱ្យគេ បំរើយ៉ាងហោចណាស់ក៏៩៩ឆ្នាំដែរ... ចំណែកឯខ្មែររាប់លាននាក់ទៀត រង់ចាំតែឱកាសសម្រាប់បះបោរដោយចង់ចេញពីភាពក្រីក្រនឹងគេដែរ, យុវជនក្នុងស្រទាប់ក្រីក្ររាប់លាននាក់ទៀត រស់ជាពលករចំណាកស្រុកឯបរទេស ក៏ព្រោះតែចង់រស់មានជីវភាពសមរម្យនឹងគេ, មាតាបីតាអ្នកទាំងនោះ រាប់លាននាក់ទៀត រស់នៅគ្មានយោបល់ជាអ្នកមើលចៅស្រីប្រុសឱ្យរៀនសូត្រទាំងគ្មានការថែរទាំត្រឹមត្រូវទាំងចៅៗ នឹងទាំងខ្លួនឯងជាចាស់ជរាទៅហើយនោះ, សាលារៀន ពេទ្យព្យាបាល ម្ហូបអាហារ នឹងទីផ្សារលក់ទំនិញ...ក៏មានសម្រាប់អ្នកមាននឹងសម្រាប់អ្នកក្រដែរ...។ល។ ជីវភាពមិនស្មើគ្នារវាងខ្មែរនឹងខ្មែរនេះ គឺជាវិបត្តិរបស់ប្រទេស ដែលប្រុងតែនឹងផ្ទុះ ពេលណាក៏មិនដឹង ពីព្រោះគេទាមទារការផ្លាស់ប្តូរ ដែលប្រទេសបានសន្យាថា"ឱ្យសន្តិភាពនឹងរីកចំរើនដល់គេ"កាលពីឆ្នាំ១៩៩៣... រចនាសម្ព័ន្ធដែលមានបក្សប្រឆាំងសម្រាប់ទប់ទល់លទ្ធិផ្តាច់ការនិយម បានត្រូវបក្សកាន់អំណាច នឹងបក្សប្រឆាំងខ្លួនឯងជាអ្នករំលាយចោលរលាយទាំងខ្លួនឯងទៅជាមួយផង ។ពេលនេះ ខិតខំក៏សាងបក្សប្រឆាំងឡើងវិញ យ៉ាងលំបាក ហាក់ដូចជាមានវិធីតែមួយគត់

តទៅទំព័រទី ១៥


# គ្មានសហបង់ថ្លៃ — ជារៀងរហូត

គ្មានការបង់ថ្លៃសម្រាប់ការណាត់ជួបវេជ្ជបណ្ឌិត គ្មានការបង់ថ្លៃសម្រាប់ការថែទាំធ្មេញ គ្មានការបង់ថ្លៃសម្រាប់សេវាថែទាំភ្នែក

Senior Whole Health (HMO SNP) គឺជាផែនការសុខភាព Medicare Advantage មួយសម្រាប់ជនជរាអាយុ 65 ឆ្នាំឡើងទៅដែលមាន Medicare និង MassHealth Standard។ សមាជិកទទួលបានអត្ថប្រយោជន៍ Medicare និង MassHealth ទាំងអស់របស់ពួកគេ រួមទាំងការធានារ៉ាប់រងលើឱសថមានវេជ្ជបញ្ជា Part D។ លើសពីនេះ យើងបន្ថែមច្រើនទៀតដូចជា៖

- ប័ណ្ណអ្នកមានសុខភាពល្អ (Healthy You Card) ដើម្បីទិញថ្នាំគ្មានវេជ្ជបញ្ជា និងទំនិញទាក់ទងនឹងសុខភាពមួយចំនួន *(អ្នកទទួលបាន $100 ក្នុងមួយឆមាស រហូតដល់ $400 ក្នុងមួយឆ្នាំ)*
- អ្នកផ្តល់ជំនួយតាមផ្ទះជួយអ្នកក្នុងរឿងចំណីអាហារ និងការចល័ត
- ការធ្វើដំណើរទៅមកពីកន្លែងណាត់ជួបពិនិត្យសុខភាព
- សមាជិកម្នាក់ៗទទួលបានអ្នកគ្រប់គ្រងសេវាថែទាំសុខភាពដែលសម្របសម្រួលការមើលថែទាំរបស់អ្នក ដើម្បីឆ្លើយតបនឹងតម្រូវការជាបុគ្គលរបស់អ្នក




=




គម្រោងមួយ។ ប័ណ្ណមួយ។ **Senior Whole Health**។

*Senior Whole Health គោរពតាមច្បាប់ស្តីពីសិទ្ធិពលរដ្ឋសហព័ន្ធ ដែលត្រូវអនុវត្ត និងមិនរើសអើងពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទឡើយ។ ATTENTION: If you speak a language other than English, language assistance services, free of charge, are available to you. Call 1-888-794-7268 (TTY 711). ATENCIÓN: si hablas español, tienes a su disposición servicios gratuitos de asistencia lingüística. Llame al 1-888-794-7268 (TTY 711). ATENÇÃO: Se fala português, encontram-se disponíveis serviços linguísticos, grátis. Ligue para 1-888-794-7268 (TTY 711).*

Senior Whole Health (HMO SNP) និង Senior Whole Health NHC (HMO SNP) គឺជាផែនការថែទាំសម្របសម្រួលជាមួយនឹងកិច្ចសន្យាអត្ថប្រយោជន៍ Medicare និងកិច្ចសន្យាជាមួយរដ្ឋម៉ាសាជូសេត/កម្មវិធីសុខភាពសាធារណៈ EOHHS MassHealth។ ការចុះឈ្មោះអាស្រ័យលើការបន្តកិច្ចសន្យារាល់ឆ្នាំ។ ផែនការនេះអាចប្រើបានសម្រាប់អ្នកដែលមានអាយុ 65 ឆ្នាំឡើងទៅដែលទទួលជំនួយវេជ្ជសាស្ត្រពីរដ្ឋនិង Medicare។ H2224_2019_71805

SWH
SENIOR WHOLE HEALTH®

Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម ហៅទូរស័ព្ទ៖
**1-888-566-3526**
**(TTY 711)**
**www.seniorwholehealth.com/SNP**
ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍

ប្រសិនបើអ្នកមាន MassHealth Standard តែពុំមានការធានា Medicare ផ្នែក A និង/ឬ ផ្នែក B ទេ អ្នកអាចនឹងមានសិទ្ធិចុះឈ្មោះក្នុងកម្មវិធី MassHealth Senior Care Options (SCO)។


កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ
AccuCare
Home Care Agency
Group Adults Foster Care Program
ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅ
ជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។
At no Cost to you
សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិក
ខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide
បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell,
Lynn, Revere, Boston និងតំបន់ជុំវិញ
ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :
• រស់នៅផ្ទះរដ្ឋ
• អាយុ ២២ ឆ្នាំឡើងទៅ
• មានសំបុត្រសុខភាព
ផលប្រយោជន៍ទទួលបាន :
• ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយ ថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
• ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
• ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ
• វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
• សមាជិកអាចទាក់ទងមក២៤ម៉ោង
To be eligibled for GAFC you must:
• live in subsidized or public housing
• age 22 years and older
• eligible for Masshealth Standard
Benefits you will get:
• personal care service in your home,
• Medication Managemant
• an individual care plan developed by a registered nurse and case manager
• ongoing monitoring of needs
• 24-hour access to services
ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

MILL CITY GROWS

Visit our Mill City Grows Mobile Market in Lowell for locally grown fruits and vegetables, including our fresh, dark leafy greens!

Lowell Community Health Center, 161 Jackson Street
Tuesdays from 11am to 2pm

Eagle Park, 92 Jewett Street (NEW!)
Saturdays from 1pm to 2:30pm

The Farm Market at Mill No. 5, 250 Jackson Street, 4th floor
Sundays from 11am to 3pm

Call **978-455-2620** or visit MillCityGrows.org for our FULL Mobile Market schedule.

Support for this program was provided in part by funds from the following organizations: Harvard Pilgrim HealthCare Foundation, American Heart Association, Tufts Health Plan Foundation, Greater Lowell Community Foundation, GLHA, MDAR, USDA, Cliff Rock Family Foundation, Lowell General Hospital



KhmerPost USA

## Now Coming to California!

The state of California has the highest concentration of Cambodians in the country with over 35% residing in the greater Los Angeles area. According to the Census Bureau, there are **116,822 Cambodians** living in California, **41,459** in Los Angeles County, and **19,784** in the City of Long Beach.

With the expansion in California, **The KhmerPost USA** will bring relevant news and information, in both Khmer and English, in the **free** biweekly newspaper publication. We have the same commitment and dedication to our readers and advertisers that we have provided for the past 10 years to the Cambodian communities in New England.

- New Format! - Monthly Magazine Style
- Local News Relevant to the greater Long Beach Area
- Excellent Advertising Opportunities
- New Completive Rates!
- For additional information call: 714.486.3060

Celebrating 10 Years of Service



**STATE OF RHODE ISLAND AND PROVIDENCE PLANTATIONS**

**Department of Corrections**

The Rhode Island Department of Corrections is now accepting applications for Correctional Officers. Starting annual salary is $52,656 with outstanding benefits and opportunities for career advancement. Candidates must be fluent in English and successfully complete a comprehensive screening process and pre-service training program.
Women and minorities are strongly encouraged to apply.
For more information call 462-JOBS or apply at NetworkRI.org.

**Correctional Officer**
APPLICATION PERIOD: May 28, 2019 – July 4, 2019

The Rhode Island Department of Corrections is an equal opportunity diversity employer.



# ការិយាល័យច្បាប់

រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ស៊ីស្កូ ជេ.រ៉ូសា



Andrew 'Bunna' Taing, Esq.
មេធាវី អែន ទ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

កំណាងក្តីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទិញលក់ផ្ទេរអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com




KhmerPost USA, LLC
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



**អគ្គនាយក សុបិន្ទ ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us



**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us



Richard Howe Jr.
Contributed Writer | Editor

**ផ្សាយពាណិជ្ជកម្ម សុបិន្ទ ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy

**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

តមកពីទំព័រទី ០១

# អង្គការ ម៉ារីម៉ាក វ៉ាលី ហ្វូតបែង...

ដោយខ្មែរផុស ស.រ.អា

ឡូវែល្ស ម៉ាសាជូសេត "អង្គការម៉ារីម៉ាក វ៉ាលី ហ្វូតបែង បាន ប្រកាសនៅថ្ងៃនេះឱ្យដឹងថា អង្គការនេះបានឧបត្ថម្ភម្តងទៀតដល់កម្មវិធីការហូបរដូវក្តៅឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម។ សម្រាប់កម្មវិធីនេះ យុវជនដែលមានអាយុ១៨ ឆ្នាំ និងដែលមានអាយុក្រោមនេះ អាចរីករាយក្នុងការហូបអាហារ និងសកម្មភាពសប្បាយរីករាយដោយសេរីមិនគិតថ្លៃ នៅទីតាំងជាច្រើនកន្លែងទូទាំងឡូវែលពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ចាប់ពីថ្ងៃទី៨ ខែកក្កដា ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។ នៅឆ្នាំ២០១៨ កម្មវិធីអាហារថ្ងៃត្រង់នៅរដូវក្តៅនេះ បានគឺដើម្បីផ្តល់អាហារដែលមានជីវជាតិដល់កុមារនៅឡូវែល និងជួយកុមារឱ្យរីករាយនឹងរដូវក្តៅដ៏សកម្ម, សុវត្ថិភាព និងសុខភាព"។

អាហារ នឹងត្រូវផ្តល់ដល់កុមារទាំងអស់ដោយមិនគិតថ្លៃ តែអ្នកមកមុន នឹងត្រូវផ្តល់អាហារមុន ដែលមានទីតាំងដូចខាងក្រោមបានចុះបញ្ជីនៅលើក្រដាសចែកផ្សាយមិនចាំបាច់ធ្វើការចុះឈ្មោះ រឺ ត្រូវមាន I.D. នោះទេ។ យោងតាមច្បាប់សិទ្ធបុគ្គលសហព័ន្ធនិងគោលនយោបាយនិងច្បាប់សិទ្ធបុគ្គលរបស់ក្រសួងសិកម្ម, ទីភ្នាក់ងារ, ការិយាល័យ និងបុគ្គលិក និងស្ថាប័ណ្ឌដែលចូលរួមក្នុងកម្មវិធីដែលគ្រប់គ្រងដោយក្រសួង ត្រូវបានហាមឃាតពី



ផ្តល់ម្ហូបនិងអាហារសំរ៉ន់ដែលសម្បូរដោយជីវជាតិ របហូតដល់ទៅ១០,៥៤៣ មុខ ដល់កុមារ ដែលបានមកចូលរួមក្នុងសកម្មភាពជាច្រើនដូចជាកម្មវិធី City parks, recreational centers, កម្មវិធីអប់រំនៅរដូចក្តៅ, និងកម្មវិធីយុវជនក្នុង កំឡុងរដូវក្តៅ។ លោកស្រី តាមម៉ី ដូបឺស (Tammie Dubois) បានមានប្រសាសន៍ថា "យើងបានសហការជាមួយដៃគូរក្នុងស្រុកដើម្បីធ្វើឱ្យធានាថា កុមារដែលបានចូលរួមកម្មវិធីការផ្តល់អាហាររដូវក្តៅយល់ដឹងពីការហូបអាហារដែលផ្តល់សុភាព និងការរក្សារាងកាយឱ្យមានភាពសកម្មរឹងមាំ។ អត្ថិភាព និងបេសកកម្មរបស់អង្គការម៉ារីម៉ាក វ៉ាលី ហ្វូតបែង ការរើសអើមលើជាតិសាសន៍, ពណ៌សំបុល, ជាតិសាសន៍, ភេទ, ពិការភាព? អាយុ រឺ ការសងសឹកចំពោះសកម្មសិទ្ធបុគ្គលក្នុងកម្មវិធី រឺសកម្មភាពណាមួយ ដោយរៀបចំឡើង រឺផ្តល់ការឧបត្ថម្ភដោយក្រសួងសិកម្ម។

ស្ថាប័ននេះគឺជាអង្គការដែលផ្តល់ឱកាសស្មើភាពគ្នា។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វ៉ិបសាយ www.mvfb.org រឺអាចទំនាក់ទំនងលេខទូរស័ព្ទលេខ 978-454-7174 រឺអ៊ីម៉ែល tdubois@mvfb.org.

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**




ជារឿងមួយដែល ខ្ញុំបានស្តាប់ការរៀបរាប់ពីសំណាក់ មិត្តម្នាក់នៅពេលដែលខ្ញុំមកដល់ស្រុកបារាំងជាដំបូង នៅ ម៉ាក្សី អ្នកដែលនិទានរៀបរាប់រឿងនេះ ជាវេជ្ជបណ្ឌិតម្នាក់ ធ្វើការនៅមន្ទីរពេទ្យកុងស៊ុបស្យុងនៅម៉ាក្សី តែម្តង ។ ដំណើររឿងមានដូចតទៅ:

ដើម្បីងាយស្រួល និងស្តាប់អោយបានពិរោះ ខ្ញុំសូមប្រឌិតឈ្មោះ អ្នកដែលមានជាប់ទាក់ទងនៅក្នុងរឿងនេះទាំងអស់ ។

**រឿងទី១ : មធ្យោបាយដោះទ័ល**

អាឃីវ ជាយុវជនមួយរូប ដែលមកបំពេញវិជ្ជានៅស្រុកបារាំងតាំងពីប្រទេសយើងមិនទាន់ធ្លាក់ទៅក្នុងព្រឹត្តិការណ៍ដ៏ខ្មៅកខ្វក់ម្លេះ ។

ថ្ងៃអាទិត្យមួយជាថ្ងៃសម្រាក អាឃីវ មកជួបនឹងមិត្តគេ ៣នាក់ នៅផ្ទះនាយ ប្រាជ្ញ ជានិស្សិតម្នាក់ ដែលជាអ្នកមានគ្រួសារនឹងមានកូន១ ហើយចូលចិត្តនិយាយរឿងកំប្លុកកំប្លែងណាស់ ។ នាយប្រាជ្ញ ជាវេជ្ជបណ្ឌិតម្នាក់ដែលបានរៀនចប់ ចេញពីមហាវិទ្យាល័យវេជ្ជសាស្ត្រផ្នែករោគស្ត្រី ហើយដែលបានធ្វើការនៅមន្ទីរពេទ្យកុងស៊ុបស្យុង នៅម៉ាក្សី ។ មិត្តអាឃីវ ៣នាក់ទៀត កំពុងបំពេញវិទ្យានៅមហាវិទ្យាល័យឱសថសាស្ត្រ ឡាទីមន នៅម៉ាក្សី មិត្តគេទាំង៣នាក់នេះ ២នាក់នៅលីវ ម្នាក់គេឱ្យនាមថា អាប៉េកាំង ព្រោះវាមានមាឌធំ ហើយជាកូនចិននៅស្រុកខ្មែរ, ម្នាក់ទៀតមានភរិយាហើយមានមាឌតូចស្គម ពាក់វ៉ែនតា មានប្រពន្ធគេ ឱ្យរហ័សនាមថា អាឆ្អឹង ។ មិត្តទី៣ នៅលីវដែរ មានភ្នែកតូចពាក់វ៉ែនតា មាឌក្រអាញធាត់ គេហៅថា អាជ្រូក ព្រោះមិនសូវនិយាយស្តីចូលចិត្តសើច និងស៊ី ។ នៅពេលដែលជួបជុំគ្នា នាយប្រាជ្ញ ក៏ចាប់ផ្តើមនិយាយរៀបរាប់សើចលេង ដូចជាពេលធម្មតា។ ដោយប្រពន្ធ នាយប្រាជ្ញ និងភរិយា អាឆ្អឹង មិននៅផ្ទះ។

**នាយប្រាជ្ញ និយាយថា :**

**អាឃីវ សួរគាត់ថា :**

-បងប្រាជ្ញ ខ្ញុំសូមសួររឿងមួយមុនសិន ជាយូរហើយខ្ញុំចង់សួរ បងតែ ពេលវេលាចេះតែ មិនសូវហុចអោយ ។

**-នាយប្រាជ្ញ ឆ្លើយ :**

**-ចង់ដឹងរឿងអ្វី? សួរមកចុះ !**

អាឃីវសួរថា :

កាលបងនៅជានិស្សិត បងមានគំនិតយ៉ាងណា? បានជាចង់ធ្វើវេជ្ជបណ្ឌិតខាងរោគស្ត្រី?

នាយប្រាជ្ញ សើចហើយនិយាយថា : រឿងខ្វារកង្កែប!



-ព្រោះកាលខ្លួន នៅពីក្មេងមួយថ្ងៃៗ ដេកស្រម័យ ចង់មើលស្រីស្រាត នទល ចង់ស្ទាបអង្អែល អាហ្នុង ! ព្រោះខ្លួនស្រឡាញ់ និងគេងស្រម័យរាល់ៗថ្ងៃ ។ (អាឃីវសួរបន្ត)

-ចុះឥឡូវ ?

Marre! ៗៗ និយាយហើយគេក៏សើចលាន់ ។ នាយប្រាជ្ញ ក៏និយាយថា :

រឿងខ្វារកង្កែបគេចូលចិត្តតាំងពីក្មេង(ព្រោះ នាយប្រាជ្ញ ជាកូនអ្នកស្រែចំការ គេចូលចិត្តដើររកខ្វារកង្កែបមែន គេគិតថា ការដែលលូកស្ទាបកេរ្តិ៍ភេទស្ត្រី ដូចគេខ្វារកង្កែបដូច្នេះដែរ បានជាប្រើពាក្យនេះ ជាម៉ូដឺ ប៉ាស រវាងមិត្តភក្តិគេ) ។ (នាយប្រាជ្ញ និយាយបន្ត) បានហើយ ។

**-ចូលរឿងយើងវិញ!**

-ថ្ងៃនេះ ឯងមានរឿងកំប្លែង២ ចង់រៀងរាប់ប្រាប់ខ្លួនទាំងអស់គ្នា ។ នាយប្រាជ្ញ បន្ត :

អាញល់ ជានិស្សិតខ្មែរម្នាក់មករៀននៅស្រុកបារាំងផ្នែកកីឡា មុនពេលស្រុក កើតកលិយុគ។

**ថ្ងៃមួយ ញល់ មកជួបបងសួរថា :**

បងប្រាជ្ញ យប់នេះខ្ញុំចង់ទៅ វីយេព័រ សាកស្រី បារាំងម្តង តាំងមកដល់ស្រុកបារាំងនេះ ខ្ញុំមិនដែលសោះ ។ ខ្ញុំចង់សួរបងមួយ ធើយ៉ាង ម៉េចឱ្យបានស្រួលហើយយូរ ?

**នាយប្រាជ្ញ សើចហើយ និយាយថា :**

-មានថ្នាំ គេ តែ ញល់ ឯងកុំអាលប្រើអី នាមឱ្យធ្លាប់ខ្លួន សាកអីចេះ ម្តងសិនមើល !

ធ្វើយ៉ាងម៉េច? (នាយ ញល់ សួរ)

យកកៅស៊ូ ចង់នៅគ្រលាក់វាមុនប្រតិបត្តិការណ៍ សាកអីចឹងមើល! ឯងក៏ធ្លាប់ដែរ មិនជាណាស់ណាទេ តែជួយបានខ្លះដែរ!

**OK! (នាយ ញល់ ឆ្លើយ)**

ម៉ោង៨ល្ងាច នាយ ញល់ រៀបចំខ្លួន និងស្លៀកពាក់យ៉ាងហ៊ឺហារ ហើយក៏ចេញពី ស៊ីតេកាណាដា ដែលជាលំនៅដ្ឋានរបស់ខ្លួន ជិះប៊ូសទៅវីយេព័រ ។

នាយ ញល់ ដើរចុះឡើង តាមផ្លូវ ធំ,តូច, ងឿងហែម រហូតដល់ចំណត រថភ្លើង សាំងសាល្យ ពិនិត្យមើលគ្រប់ទីកន្លែង ភ្នែកសំឡឹងគយគន់មើលស្ត្រីជើងមួយជាញ្ញា ។ នាយយើង ដើររហូតដល់កាពុស្ស៊ាំងបានឃើញស្ត្រី៣នាក់ ឈរជិតជញ្ជាំងដោយយកជើងមួយជាន់លើជញ្ជាំង នាយកយើងពិនិត្យពីចំងាយ ជ្រើសរើសជាស្រេច ស្ត្រី២ នាក់ ប្លុង (blonde) ម្នាក់ទៀត ប្រ៊ុយ (brune) តែមានមាឌធំធាត់ជាងគេ ។ ដោយសារខ្លួនជា មនុស្សស្គម នាយ ញល់ ចូលចិត្តស្រីធាត់ គេសម្រេចចិត្តយកនាងធាត់ហើយ គេក៏ដើរតម្រង់ឆ្ពោះទៅរកស្ត្រីទាំង៣នាក់នោះ ធ្វើបែបហ៊ឺហារ ។

នាង សាឡុប ទាំង៣ នាក់ធ្វើព្រងើយ ព្រោះមិននឹកស្មានថា ឡឺប៉ឺ ទី ស៊ីនតុក មករកខ្លួនឡើយ ។

**នាយ ញល់ ក៏សួរថា កុមប៊ីយាង ?**

**សាឡុប ទាំង៣ ភ្ញាក់ហើយ ក៏សួរថា :**

Ah! é est á nous que cause ?

នាយ ញល់ bien sure ! á qui voulez vous que je cause il n´y a que nouse quatre.

Entre nouse 3 tu veux laquelle ?

La Brune! នាយ ញល់ ឆ្លើយ ។

D' accord ! ឡាដាម ប្រ៊ុន ឆ្លើយ ៥០ប្រាង់ !

នាយ ញល់ ត្រូវ ឡាដាម ប្រ៊ុន អូសដៃឡើងលើបន្ទប់ ខាងលើ ជិតមាត់ទ្វារ ដែលស្ត្រីទាំង៣ នាក់ឈរ ។

ឡាដាម ប្រ៊ុន និយាយបណ្តើរទាញអូសដៃបណ្តើរថា:

viens! viens! Je te bouffe crue petit comme toi ! Je te fais rentrer dans mon Q ! tu trouvera le paradis !

ឡើងដល់បន្ទប់នាង សាឡុប ប្រ៊ុន ស្រាតទុកខ្លួនឱ្យនៅទទេ នទលគក ដូចដីរទឹក ដេកលើពូក កន្ទែកជើង និយាយ ហៅនាយ ញល់ ថា: viens ! viens ! Je t'emméne au paradise ! mon petit!

**តទៅលេខក្រោយ**



# *LITTLE ROADY / From Front Page*

RIDOT contracted with May Mobility, a Michigan-based start-up, which is developing self-driving shuttles for college campuses, corporate clients, and central business districts. It launched a private corporate service in Detroit in June 2018 and a public service in Columbus, Ohio in December 2018. Rhode Island is the first state in Northeast Region to employ this research project. May Mobility has hired fleet attendants and managers from Rhode Island and has set up a local operations office in Providence.

"It's always exciting when Rhode Island has an opportunity to lead the way in cutting-edge green technology," said Governor Gina Raimondo. "This project will provide valuable data for states across the country as we move beyond conventional transit services to provide better, cleaner, and more accessible transportation for all."

In real time interactive map, a fleet of 10 electric vehicles offer rides along a fixed route in the Woonasquatucket River Corridor of Providence, running 5.3-mile loop with 12 stops between Olyneyville Square and Providence Station. The shuttle service is free with a human operator in case of abnormal functionality.

"The kickoff of this service and research project is another achievement for the new DOT," RIDOT Director Alviti said. "Our transportation agency has literally been rebuilt to effectively deliver safer roads and bridges while simultaneously studying and piloting new technologies. In doing so, we'll keep Rhode Island well ahead of the curve for the transportation solutions of tomorrow."

The project costs $1.2 million including the research component. RIDOT's contract with May Mobility with options to extend the service for two more years.

"By partnering with RIDOT, May Mobility is showing how our self-driving shuttles can be part of a sustainable future for communities," said Edwin Olson, CEO and founder of May Mobility. "Our environmentally-friendly shuttles aren't just fun-to-ride, they can increase access and convenience for a large number of people."

The shuttles use a suite of sensors -using intelligent software to navigate the route . The entire fleet has undergone 500 hours of testing both at Quonset Point this winter and in Providence this spring, which included detail mapping so the machines know every inch of its route and how to operate in a variety of traffic and weather conditions.

The shuttle service is through May 15, 2020, seven days a week except major holidays, from 6:30am - 6:30pm. A map of the route can be downloaded here: http://www.dot.ri.gov/projects/TRIP/img/LR-AV-ROUTE.jpg and an interactive map shows where the shuttles are in real time at https://providence.maymobility.com

More information about the Little Roady project can be found at www.LittleRoady.com.




# គម្រោងរថយន្តក្រុងចលនាដោយខ្លួនឯងឈ្មោះ"លីថូលរ៉ូឌី"

ប្រូវីឌិន- អភិបាលក្រុងប្រូវិដិន ជីណា រ៉ាយមុនដូ នៃរដ្ឋរ៉ូដអាយឡិន, នាយកដ្ឋានដឹកជញ្ជូន (RIDOT) ដឹកនាំដោយលោក ភីទ័រ អាល់វីទី, អមដោយមន្ត្រីរផ្លូវការរដ្ឋនឹងតំបន់ បានសម្ពោធគម្រោងរថយន្តក្រុងគ្មានអ្នកបើក"លីថូលរ៉ូឌី"កាលពីខែមុន។

នៅលើផ្លូវដែលមិនផ្លាស់ផ្តូរ រថយន្តចំនួន១០ គ្រឿង បានផ្តើមដឹកអ្នកជិះនៅតាមផ្លូវបណ្តោយស្ទឹង Woonasquatucket ក្នុងរិលវង់ចម្ងាយ ៥.៣ម៉ាយ មានចំណត១២ ពីចន្លោះ Olyneyville Square and Providence Station ។ គេអាចជិះរថនោះ បានដោយឥតយកថ្លៃហើយអ្នកបើកដែលគ្រាន់តែជំនួយការក្រែងមានការរអាក់រអួលដោយចៃដន្តតែប៉ុណ្ណោះ។

(RIDOT) បានចុះកិច្ចសន្យាជាមួយ "មេយ មូប៊ីលីទី May Mobitity" រហូតដល់ខែឧសភា ឆ្នាំ ២០២០ ដែលធ្លាប់មានរថយន្តឥតអ្នកបើតរបៀបនេះ នៅ"ខេមពីស"មហាវិទ្យាល័យ"មីឈីគេន", មានប្រើនៅ"ដេត្រយ"ក្នុងក្រុមហ៊ុនឯកជនកាលពីខែមិថុនា ២០១៨, បានប្រើជាសេវាសាធារណ នៅ"កូឡុមប៊ឹស"រដ្ឋអូហាយ៉ូ កាលពីខែធ្នូ២០១៨...ហើយនៅរ៉ូដអាយឡិន គឺជារដ្ឋទី១នាតំបន់ខាងជើងឈៀងខាកើតប្រើរថយន្តទំនើបបំផុតដែលកំពុងស្រាវជ្រាវគ្មានអ្នកបើកបរនេះ ព័តិមានបន្ថែម សូមចូលទៅ គេហទំព័រ www.Littleroady.com




Ashok Joshi, M.D.

Prema Daniel, NP

Julie Gallagher, FNP

Chantrea Yim-Bo
Office Coordinator

C.B.C Medical & Walk In Center Primary Care
មជ្ឈមណ្ឌលព្យាបាលជំងឺបន្ទាន់ C.B.C សេវាថែទាំសុខភាពជាប្រចាំ
Serving Lowell Community for 25 Years
បំរើសហគមន៍ឡូវែលអស់រយៈពេល 25 ឆ្នាំ

Accepting New Patients
Accepting ALL Insurances
- In House Lab Services
- Immunizations & Injections
- PT1 Transportation Available
- Treatment for Diabetes and Hypertension
- Physical Exams
- Emergency Room & Inpatient Hospital Follow Ups
- Wellness & Preventative Care
- Workers Comp Medical Treatment
- DOT Physicals
- Walk-In for Illness and Minor Injury

ទទួលយកអ្នកជម្ងឺថ្មី
ទទួលយកគ្រប់ធានារ៉ាប់រងទាំងអស់
* សេវាវិភាគវេជ្ជសាស្ត្រនៅនឹងកន្លែង
* ការចាក់ថ្នាំបង្ការរោគ & ថ្នាំវ៉ាក់សាំង
* មានរថយន្តសម្រាប់ធ្វើដំណើរមកដល់កន្លែងសម្រាប់ម៉ាសហិល
* ព្យាបាលជំងឺទឹកនោមផ្អែម និងលើសឈាម
* ការវិភាគរាងកាយ
* ការតាមដានអ្នកជំងឺដែលត្រូវការស្នាក់នៅមន្ទីរពេទ្យ និងការសង្គ្រោះបន្ទាន់
* ការថែទាំដើម្បីការពារ និងរក្សាសុខភាព
* ការព្យាបាលក្រោមការធានារ៉ាប់រងគ្រោះថ្នាក់ចំពោះនិយោជិក
* ការពិនិត្យរាងកាយសម្រាប់សុំប័ណ្ណបើកបរ
* អ្នកមានជំងឺ និងរងរបួសតិចតួចមិនចាំបាច់មានការណាត់ជាមុន

Our Staff Speaks Khmer and Spanish!
បុគ្គលិករបស់យើងនិយាយភាសាខ្មែរ និងអេស្ប៉ាញ

Affiliated with Lowell General for Complete Connected Care
សហការណ៍ជាមួយមន្ទីរពេទ្យ ឡូវែលជេនេរ៉ាល ដើម្បីទទួលបានការថែរក្សាឲ្យបានពេញលេញ

16 Pine Street, Unit #5 • Lowell, MA
Tel: 978-454-9703 • Fax: 978-528-2024
ទូរស័ព្ទលេខ: 978-454-9703
Open Hours: 8am - 4pm • Monday - Friday
ម៉ោងធ្វើការ: 8 am – 4 pm ថ្ងៃច័ន្ទ - សុក្រ

## តមកពីទំព័រទី ០៩ ឥទ្ធិពលចិនបច្ចុប្បន្នមកលើកម្ពុជា

គឺ"ចូលក្នុងស្រុកខ្មែរវិញដើម្បីទៅចាប់ ហ៊ុន សែន" តើនេះមិនមែនជាភាពអស់សង្ឃឹមថ្មីរបស់សហគមន៍ខ្មែរទេឬ?

តើមានអ្វីសម្រាប់ជំនួសភាពអស់សង្ឃឹមនេះទេ? នៅមានដំណោះស្រាយច្រើនទៀតដែរ ដែលទាំងអស់ត្រូវផ្តើមពីតម្លាភាពនៃក្រុមអ្នកដែលចង់ទៅដឹកនាំប្រទេស ពីព្រោះថ្វីត្បិតសកម្មភាពត្រូវធ្វើនៅក្នុងប្រទេសក៏ដោយក្តី តែអ្នកតស៊ូដែលជាអ្នកប្រយុទ្ធមុនគេ អ្នកចេះនឹងអ្នកគាំទ្រដែលផ្តល់ធនធានមុនគេបាននៅក្រៅប្រទេសអស់ទៅហើយ ដូច្នេះគឺត្រូវ"បង្រួបបង្រួមកម្លាំងដឹកនាំដោយភាពស្មោះត្រង់ឱ្យខាងតែបាន"។សង្គ្រោះជាតិពិតប្រាកដ មិនទាន់ស្លាប់នៅឡើយទេ-អ្នកគាំទ្រសង្គ្រោះជាតិនោះក៏គេកំពុងតែរង់ចាំតែ"សម រង្ស៊ី-កឹម សុខា រួមគ្នាយ៉ាងពិតប្រាកដ" តែប៉ុណ្ណោះ កម្លាំងសាមគ្គីនោះ នឹងចេញមកវិញដូចនៅឆ្នាំ២០១៧ សហគមន៍អន្តរជាតិក៏នឹងផ្តល់ដំណោះស្រាយជាដង្ហើប ដែលនឹងប្តូរស្ថានភាពនយោបាយក្នុងប្រទេសបាននៅឡើយ។ ឆ្នាំ២០១៨-១៩នេះជាឆ្នាំដែលសង្គ្រោះជាតិ សម រង្ស៊ី ទៅបំបែក"សង្គ្រោះជាតិពិតប្រាកដ"ជាចម្រៀកចេញពីក្រុមសង្គ្រោះជាតិ កឹម សុខា ហើយប្រវញ្ចយកផលតែម្នាក់ឯង ហើយទង្វើនេះ បានត្រូវអ្នកតស៊ូឯទៀតៗគេមើលឃើញហើយថយឱ្យឆ្ងាយពី"គំនិតលាក់ពុត"នេះ តែក៏មិនមែនគេនៅដេកនៅស្ងាត់ស្ងៀម ដូចដែលការឃោសនាប្រឌិតឡើងនោះទេ ។

ឥទ្ធិពលចិនមកលើកម្ពុជាមិនទាន់ជា"អវិជ្ជមាន" កែរមិនឡើងទេ ពីព្រោះចិនមករកស៊ីនៅប្រើច្បាប់ខ្មែរនៅឡើយ... ដូច្នេះបើចង់ឈ្នះពិតប្រាកដនោះត្រូវបូជាជីវិតចុងក្រោយរបស់ សម រង្ស៊ី នឹង កឹម សុខា ជូនសន្តិភាពប្រជាជាតិ មិនមែនទៅឱ្យទាហ៊ាន ហ៊ុន សែន បាញ់លេងទទេៗនោះទេ, គឺប្តេជ្ញាស្តារវិបត្តិផ្ទៃក្នុងខ្លួនឯង ប្រកបដោយភាពស្មោះត្រង់នឹងគ្នាទៅវិញទៅមកកម្លាំងនឹងកើនឡើងវិញ ។ ចំណែកក្រុមលោក ហ៊ុន សែន វិញ ក៏កាន់តែជ្រៃដូចតែគ្នា ក៏ល្មមស្វែងរកចិត្ត"ត្រជាក់ៗ"ខ្លះទៅ... ចំណែកឯទំពាំងស្នងឬស្សីរបស់ទាំងអស់គ្នាវិញ ក៏មិនទាន់រឹងមាំនៅឡើយទេ ហេតុអ្វីក៏ចង់រក្សាព្យាយាមឱ្យប្រជាជនគុំគួនលើអ្នកទៅកាន់អំណាចអីក៏យូរម្លេះ? ចង់ឈ្នះគ្នាដោយចម្បាំង ឬដោយការគុំគួនបំផ្លាញគ្នាទំនងជាហួសសម័យហើយ ពីព្រោះវានឹងមិនចេះចប់ទេ! សន្តិភាពប្រាកដជាអាចត្រឡប់មកវិញបាន សម្រាប់ទាំងអស់គ្នា បើសុខចិត្តដកថយតែ១ជំហ៊ានម្នាក់ ហើយមិនបន្តតាំងខ្លួនថា អញជា"ព្រះឥន្ទ"ទេនោះ។

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត
URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន
Residential Leasing Center

ដាញ៉ែល តាន
ភ្នាក់ងារអចលនៈទ្រព្យ
Daniel Tan
Real Estate Agent
Cell: 978-902-6354
508 Westford Street • Lowell, MA 01851
(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនសួរិន អេជេនស៊ី
KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business

508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com




# DIVERSITY
## ADULT DAYCARE CENTER

"ទីកន្លែងដែលអ្នកជាទីស្រលាញ់របស់លោកអ្នក អាចហៅថា ជាផ្ទះ"

**តើអ្វីទៅជាមជ្ឈមណ្ឌលថែទាំចាស់ជរា?**

យើងខ្ញុំយល់ឃើញថាក្នុងនាមជាអ្នកផ្តល់សេវាថែទាំពេញម៉ោង គឺជាការងារមិនងាយស្រួលនោះទេ។ នៅពេលពអ្នកជាទីស្រឡាញ់ដែលមានវ័យកាន់តែចាស់ ត្រូវការការថែទាំ រឺការមើលការខុសត្រូវក្នុងកំឡុង ពេលព្រឹក រឺពេលថ្ងៃនោះ វាអាចបង្កើតឱ្យមានអារម្មណ៍ស្មុកស្មាញដល់អ្នកមើលថែក្នុងគ្រួសារ។ គ្រួសារជាច្រើនគិតថាពួកគេគ្មានជម្រើសអ្វីក្រៅពីឈប់ធ្វើការងារ រឺឱ្យមានអ្នកមកមើលថែអ្នកដែលជា ស្រលាញ់របស់ខ្លួនដល់លំនៅដ្ឋាន រឺកន្លែងថែរទាំចាស់ជរា។ មជ្ឈមណ្ឌលថែទាំចាស់ជរា ដាយហ្វ័រស៊ីធី ដែលភាសាអង់គ្លេស Diversity Adult Daycare Center (DADC) មានផ្តល់ទីកន្លែងគ្រប់គ្រងដែលមានសុវត្ថិភាពដែលអ្នកដែលមានវ័យចំណាស់អាចធ្វើការទាក់ទងនឹងមនុស្សឯទៀត, រីករាយជាមួយនឹងសកម្មភាពផ្សេងៗ និងទទួលបានជំនួយថែទាំ។ ទីកន្លែងនេះវានឹងមិនធ្វើឱ្យលោកអ្នក ដែលជាអ្នកមើលការខុសត្រូវចំពោះពួកគាត់មានការបារម្ភអ្វីទាំងអស់ នៅពេលពួកគេមានការណាត់ជួប, ភារៈកិច្ចការងារ រឺមានពេលវេលាសម្រាប់ខ្លួនឯងខ្លាល់ផងដែរ។

**អត្ថប្រយោជន៍នៃសេវាថែទាំចាស់ជរា**

ចូលរួមជាមួយនឹងមជ្ឈមណ្ឌលថែទាំចាស់ជរា នឹងមានអត្ថប្រយោជន៍វិជ្ជមានជាច្រើនដល់ជនចាស់ជរា។ អ្នកជាទីស្រលាញ់ក្នុងគ្រួសាររបស់លោកអ្នកមិនចាំបាច់នៅផ្ទះដែលធ្វើឱ្យមានអារម្មណ៍ឯកកោរដោយគ្មានការជុំរុញលើកទឹកចិត្តផ្នែកស្មារតីនោះទេ នៅពេលអ្នកមើលថែទាំងពួកគាត់ជាប់រវល់។ ការមកកាន់មជ្ឈមណ្ឌលថែទាំចាស់ជរាបង្កើតឱ្យមាននូវអារម្មណ៍ថា ស្ថិតនៅក្នុងសហគមន៍មួយដែលពួកគាត់អាចមានភាពរីករាយ និងមាននូវសុខភាពល្អជាមួយនឹងសកម្មភាពជាច្រើននៅក្នុងមជ្ឈមណ្ឌល។ អ្នកជាទីស្រឡាញ់របស់លោកអ្នកនឹងទទឹមរង់ចាំក្នុងការទទួលបានឯករាជ និងជួបជាមួយនឹងមិត្តភ័ក្រ្ត។ មេត្រីភាពដែលលោកអ្នកមានជារៀងរាល់ថ្ងៃជំរុញឱ្យមានអារម្មណ៍នូវតំលៃខ្លួនឯង និងមិត្តភាព។

**សេវាកម្មដែលយើងខ្ញុំផ្តល់ជូននៅ DADC:**

- អាហារ និងនំចំណីបំប៉នច្រើន
- ថ្នាក់កីឡាជាក្រុម
- ថ្នាក់សម្រាប់ការសិក្សា
- ដំណើរកំសាន្ត និងការចេញទៅខាងក្រៅជាក្រុម
- ការលេងល្បែងកំសាន្ត និងសកម្មភាពរីករាយប្រចាំថ្ងៃ ជំនួយក្នុងការថែទាំ
- សេវាផាតមុខ និងធ្វើសក់
- ការដឹកជញ្ជូន
- ការរៀបចំកម្មវិធីខួបកំណើតប្រចាំខែ
- បុគ្គលិកផ្នែកពេទ្យ
- សកម្មភាពដាំបន្លែ

**តើនរណាជាបេក្ខភាពសមស្របសម្រាប់មជ្ឈមណ្ឌលថែទាំចាស់ជរា DADC**

- មានអាយុចាប់ពី ៥៥ និងចាស់ជាងនេះ
- ជនជាតិអាស៊ីអាគ្នេយ៍ និងស្ពិនធីស
- ទីតាំងយើងខ្ញុំងាយស្រួលសម្រាប់ជនពិការចេញចូលច

**របៀបនៃការបង់ប្រាក់ដែលយើងខ្ញុំទទួលយក**

- យើងខ្ញុំទទួលយកការបង់ប្រាក់ជាឯកជន
- ទទួលយករាល់ធានារ៉ាប់រងចំបងៗទាំងអស់

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

យើងខ្ញុំនិយាយភាសាអង់គ្លេស, ស្ពេននីស, ខ្មែរ, ឡាវ, ម៉ោង, ប៉ទុយក្កាល់, សូវៀត និងតាហ្កាលុក។ សូមអញ្ជើញមកទស្សនាកន្លែងមជ្ឈមណ្ឌលយើងខ្ញុំ។ យើងខ្ញុំនឹង ផ្តល់នូវការពិនិត្យវាយតំលៃ និងជំនួយក្នុងការដាក់ពាក្យដោយមិនគិតថ្លៃ។ ទទួលយករាល់ការធានារ៉ាប់រងចំបងៗ និងការទូទាត់ប្រាក់ជាឯកជនទាំងអស់។ សម្រាប់ធានារ៉ាប់រង មេឌីឃេត សម្រាប់សេវាថាទាំចាស់ជរាលោកអ្នកមិនចាំបាច់ចំណាយអ្វីទាំងអស់។